ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធី
# នៃការអធ្វោតជាននិងការដកហូតម្ហូបអាហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាននិងការដកហូតម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ក្នុងគោលបំណងដើម្បីការពារសុខភាពនិងផលប្រយោជន៍អ្នកប្រើប្រាស់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ម្ហូបអាហារ** សំដៅដល់ផលិតផលឬសារធាតុណាមួយ ទោះបីត្រូវកែច្នៃទាំងស្រុង ឬពាក់កណ្តាលកែច្នៃ ឬមិនទាន់កែច្នៃ សម្រាប់មនុស្សបរិភោគ រួមទាំង ភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុទាំងឡាយដែលត្រូវបានប្រើប្រាស់នៅក្នុងផលិតកម្ម ការរៀបចំ ឬការធ្វើប្រព្រឹត្តកម្មនៃម្ហូបអាហារ លើកលែងតែគ្រឿងសម្អាង ផលិតផលថ្នាំជក់ ឬផលិតផលដែលប្រើប្រាស់សម្រាប់ឱសថ។

២- **ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ** សំដៅដល់ម្ចាស់អាជីវកម្មម្ហូបអាហារ ឬបុគ្គលដែលត្រូវបានប្រគល់សិទ្ធិក្នុងការប្រតិបត្តិអាជីវកម្មម្ហូបអាហារ ឬបុគ្គលទទួលខុសត្រូវលើអាជីវកម្មម្ហូបអាហារ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដូចជាផលិតករ អ្នកកែច្នៃ អ្នកវេចខ្ចប់ អាជីវករលក់ដុំ អាជីវករចែកចាយ និងអាជីវករលក់រាយ ជាដើម។

៣- **ការដកហូតម្ហូបអាហារ** សំដៅដល់ការអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងការប្រមូលម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលចរាចរនៅតាមបណ្តាទីផ្សារ និងនៅតាមដំណាក់កាលផ្សេងៗនៃខ្សែច្រវាក់ម្ហូបអាហារនោះ រួមទាំងការចែកចាយ ការស្តុកទុក ការផ្តល់សេវាម្ហូបអាហារ ការផ្តល់ជាអំណោយ ការវេចខ្ចប់ និងការកែច្នៃ ក្នុងគោលបំណងការពារសុខភាពនិងផលប្រយោជន៍អ្នកប្រើប្រាស់។

៤- **ការដកហូតម្ហូបអាហារដោយប្រតិបត្តិករអាជីវកម្មម្ហូបអាហារខ្លួនឯង** សំដៅដល់សកម្មភាពដែលបុគ្គលណាមួយធ្វើការប្រមូលមកវិញនូវម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ហើយមិនត្រូវចាត់ទុកជាការដកហូតម្ហូបអាហារដោយខ្លួនឯងនោះទេ ប្រសិនបើសកម្មភាពនោះធ្វើឡើងតាមរយៈការព្រមានឬជូនដំណឹងជាមុនដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច។

៥- **ការដកហូតម្ហូបអាហារដោយអាជ្ញាបញ្ជា** សំដៅដល់សកម្មភាពដែលបុគ្គលណាមួយធ្វើការប្រមូលមកវិញនូវម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស តាមរយៈការបញ្ជាដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយផ្អែកតាមភស្តុតាងឬអំណះអំណាងជាក់លាក់។

៦- **ស្លាកសញ្ញា** សំដៅដល់ស្លាក យីហោ ម៉ាក ជារូបភាពឬជាការពិពណ៌នាជាលាយលក្ខណ៍អក្សរ ជាការបោះពុម្ព ការបោះពុម្ពដោយប្រើស្ពិនស៊ីល ការគូសសម្គាល់ ធ្វើឱ្យក្រឡោត ឬរំលេចនៅលើ ឬភ្ជាប់ទៅនឹងវត្ថុសម្រាប់ដាក់ឬសម្បកវេចខ្ចប់សម្រាប់ដាក់សេចក្តីពិពណ៌នាលាយលក្ខណ៍អក្សរ ផ្សេងៗទៀតដែលបានបោះពុម្ព បិទ សម្គាល់ ឬក៏បង្ហាញ ឬភ្ជាប់ជាមួយសម្បកវេចខ្ចប់ ឬកំប៉ុង ម្ហូបអាហារ។

៧- **ម្ហូបអាហារវេចខ្ចប់ស្រេច** សំដៅដល់ម្ហូបអាហារដែលបានវេចខ្ចប់នៅក្នុងសម្បកវេចខ្ចប់សម្រាប់ ផ្ទុកបម្រុងដើម្បីបញ្ជូនទៅឱ្យអ្នកប្រើប្រាស់ឬដើម្បីគោលបំណងសម្រាប់ចែកចាយ។

៨- **ការដកនិងកែតម្រូវសន្និធិឡើងវិញ** សំដៅដល់ការដកចេញឬការកែតម្រូវម្ហូបអាហារដែលគ្មាន សុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលមិនទាន់ចែកចាយទៅក្នុងទីផ្សារឬដែល ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមហ៊ុននៅឡើយ។

៩- **ការអង្កេតដាន** សំដៅដល់ប្រព័ន្ធតាមដានការធ្វើចរាចរនូវម្ហូបអាហារតាមដំណាក់កាលផលិតកម្ម ការកែច្នៃ និងការចែកចាយ។

១០- **ម្ហូបអាហារដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់ម្ហូបអាហារដែលមិនបំពេញ លក្ខខណ្ឌតម្រូវតាមបទប្បញ្ញត្តិបច្ចេកទេសនានាជាធរមាន។

១១- **ម្ហូបអាហារគ្មានសុវត្ថិភាព** សំដៅដល់ម្ហូបអាហារដែលបង្កហានិភ័យដល់អ្នកប្រើប្រាស់បន្ទាប់ពីបាន ទទួលទាន ដោយម្ហូបអាហារនោះមានផ្ទុកសារធាតុបង្កគ្រោះថ្នាក់ ដូចជារូបវន្ត គីមី ជីវៈ និងការ ចម្លងសារធាតុផ្សេងៗទៀត។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### មាត្រា៤ ._

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចដឹកនាំ សម្របសម្រួលការគ្រប់គ្រងការអង្កេតដាន និងការដកហូត ម្ហូបអាហារ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្រសួងពាណិជ្ជកម្មមានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការ ក្លែងបន្លំ ដែលសរសេរកាត់ថា «ក.ប.ប.» ជាសេនាធិការលើការងារអង្កេតដាននិងការដកហូតម្ហូបអាហារ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៣
## ភារកិច្ចរបស់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ

### មាត្រា៥ ._

រាល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវអនុវត្តការដកហូតម្ហូបអាហារ បន្ទាប់ពីបានដឹងឬទទួលព័ត៌មាន ថាម្ហូបអាហាររបស់ខ្លួនគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ឬបន្ទាប់ពីទទួលបានការបញ្ជា ពីក្រសួងពាណិជ្ជកម្មឱ្យដកហូតម្ហូបអាហារ។

### មាត្រា៦ ._

រាល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវអនុវត្តការដកហូតនូវម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិន អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសឱ្យមានប្រសិទ្ធភាពខ្ពស់និងត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

ក- រៀបចំប្រព័ន្ធអង្កេតដានដែលអាចកំណត់អត្តសញ្ញាណក្រុមហ៊ុនឬបុគ្គលដែលធ្វើការផ្គត់ផ្គង់ឬទទួលបានការផ្គត់ផ្គង់ម្ហូបអាហារ ចំពោះផលិតផលនាំចូលឬផលិតផលក្នុងស្រុក ហើយប្រព័ន្ធនេះត្រូវកំណត់នូវនីតិវិធីដែលអាចផ្តល់លទ្ធភាពឱ្យក្រសួងពាណិជ្ជកម្មនិងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារផ្សេងទៀតទទួលបានព័ត៌មាននៃការអង្កេតដានគ្រប់ពេលវេលា។

ខ- ដាក់ស្លាកសញ្ញានិងកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ចំពោះម្ហូបអាហារដែលចរាចរលើទីផ្សារ ដើម្បីផ្តល់ភាពងាយស្រួលដល់ការអង្កេតដាន។ ក្រសួងពាណិជ្ជកម្មនិង/ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវកំណត់គោលការណ៍ណែនាំអំពីប្រព័ន្ធអង្កេតដាន ការបិទស្លាកសញ្ញានិងការកំណត់អត្តសញ្ញាណផលិតផលម្ហូបអាហារ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធ។

បែបបទនិងនីតិវិធីនៃការអង្កេតដាន ត្រូវកំណត់ដោយប្រកាសរបស់ប្រធានក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា៧ .-**

រាល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវបង្កើតនីតិវិធីចាំបាច់នានារបស់ខ្លួន ចំពោះម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ហើយនីតិវិធីទាំងនោះត្រូវឆ្លើយតបយ៉ាងពេញលេញចំពោះការដកហូតម្ហូបអាហារពាក់ព័ន្ធចេញពីដំណាក់កាលផ្សេងៗនៃខ្សែច្រវាក់ម្ហូបអាហារ។

ការដកនិងការកែតម្រូវសន្និធិឡើងវិញនូវម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស មិនចាត់ទុកជាការដកហូតម្ហូបអាហារ ហើយមិនតម្រូវឱ្យមាននីតិវិធីនៃការដកហូតម្ហូបអាហារនោះទេ។

**មាត្រា៨ .-**

រាល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវជូនដំណឹងដល់អ្នកលក់ អតិថិជន និងអ្នកប្រើប្រាស់ តាមរយៈសេចក្តីប្រកាសព័ត៌មាន ខិត្តប័ណ្ណ ប្រព័ន្ធផ្សព្វផ្សាយ សារអេឡិចត្រូនិក លិខិត ទូរសារ ទូរស័ព្ទ ឬតាមរយៈប្រព័ន្ធទំនាក់ទំនងផ្សេងៗទៀត អំពីការដកហូតម្ហូបអាហារឱ្យបានលឿនបំផុត និងមិនឱ្យលើសរយៈពេល២(ពីរ) ថ្ងៃឡើយ។ ការជូនដំណឹងនេះ ត្រូវភ្ជាប់នូវព័ត៌មានដូចខាងក្រោម៖

ក- ឈ្មោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលត្រូវដកហូត។

ខ- ឈ្មោះម្ហូបអាហារដែលត្រូវដកហូត។

គ- ម៉ាកម្ហូបអាហារដែលត្រូវដកហូត។

ឃ- លេខឡូត៍ ទំហំ និងប្រភេទសម្បកវេចខ្ចប់និងបរិមាណម្ហូបអាហារដែលបានចែកចាយ។

ង- សេចក្តីលម្អិតអំពីមូលហេតុនៃការដកហូតម្ហូបអាហារ រួមទាំងហានិភ័យដែលអាចកើតមានឡើងការបង្កគ្រោះថ្នាក់ ឬការមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។

ច- ហានិភ័យដែលអាចប៉ះពាល់សុខភាព។

ឆ- សេចក្តីណែនាំអតិថិជនឬអ្នកប្រើប្រាស់ពីការអនុវត្តនានាចំពោះម្ហូបអាហារដែលត្រូវដកហូត។

ជ- សារព្រមានជាក់លាក់ចំពោះម្ហូបអាហារដែលត្រូវដកហូតនិងបម្រាមដាច់ខាតក្នុងការប្រើប្រាស់ដែលត្រូវសរសេរជាអក្សរពុម្ពពណ៌ក្រហម។

ឈ- លេខទូរស័ព្ទទំនាក់ទំនង។

## ជំពូកទី៤
## ចំណាត់ថ្នាក់និងនីតិវិធីនៃការដកហូតម្ហូបអាហារ

**មាត្រា៩ .-**

ចំណាត់ថ្នាក់នៃការដកហូតម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស រួមមាន៖

ចំណាត់ថ្នាក់ទី១ : ជាករណីនៃការប្រើប្រាស់ម្ហូបអាហារដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពធ្ងន់ធ្ងរ ឬបណ្តាលឱ្យបាត់បង់ជីវិត។

ចំណាត់ថ្នាក់ទី២ : ជាករណីនៃការប្រើប្រាស់ម្ហូបអាហារដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពកម្រិតស្រាលឬកម្រមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។

ចំណាត់ថ្នាក់ទី៣ : ជាករណីនៃការប្រើប្រាស់ម្ហូបអាហារដែលមិនអាចបង្កគ្រោះថ្នាក់ដល់សុខភាពសុវត្ថិភាពរបស់អ្នកប្រើប្រាស់ទេ ប៉ុន្តែមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។

**មាត្រា១០ .-**

នីតិវិធីនៃការដកហូតម្ហូបអាហារ អនុវត្តដោយប្រតិបត្តិករអាជីវកម្មម្ហូបអាហារខ្លួនឯង រួមមាន៖

ក- ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវធ្វើការដកហូតម្ហូបអាហារដោយខ្លួនឯងឬតាមរយៈអ្នកចែកចាយ អ្នកនាំចូល អ្នកនាំចេញ អ្នកប្រើប្រាស់ បុគ្គលពាក់ព័ន្ធ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយ នៅពេលរកឃើញថាម្ហូបអាហាររបស់ខ្លួនគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស។ ក្នុងករណីនេះ ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងពាណិជ្ជកម្មនិងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអារហារផ្សេងទៀត តាមរយៈទម្រង់និងបែបបទនៃការដកហូតនូវម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស បន្ទាប់មកត្រូវអនុវត្តដំណើរការដកហូតភ្លាម។

ខ- បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងស្តីពីការដកហូតម្ហូបអាហារពីប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ក្រសួងពាណិជ្ជកម្មត្រូវឆ្លើយតបមិនលើសពីរយៈពេល២(ពីរ)ថ្ងៃ ដោយត្រូវកំណត់ចំណាត់ថ្នាក់ម្ហូបអាហារដកហូត ហើយត្រូវចាត់វិធានការជាបន្ទាន់។

គ- ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវចាត់វិធានការផ្អាកផលិតកម្ម ការនាំចូល ការចែកចាយ និងការធ្វើអាជីវកម្មនៃឡូត៍ទំនិញប៉ះពាល់ទាំងនោះ។ ដោយឡែក ឡូត៍ផ្សេងទៀតនៃមុខទំនិញដូចគ្នាត្រូវអនុវត្តវិធានការដូចគ្នា លើកលែងតែលទ្ធផលវិភាគនៃឡូត៍ផ្សេងទៀតនៃមុខទំនិញដូចគ្នានោះត្រូវបានអនុញ្ញាតដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ឃ- ចំពោះម្ហូបអាហារនាំចូល ការដកហូតម្ហូបអាហារត្រូវអនុវត្តដោយបុគ្គលធ្វើធុរកិច្ចម្ហូបអាហារដោយខ្លួនឯង ផ្អែកលើព័ត៌មានពីស្ថាប័នអន្តរជាតិទទួលបន្ទុកសុវត្ថិភាពម្ហូបអាហារ ពីអ្នកប្រើប្រាស់ អ្នកចែកចាយ ឬប្រភពផ្សេងៗទៀត។

ង- ក្នុងករណីប្រតិបត្តិករអាជីវកម្មម្ហូបអាហារមិនចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌ "ឃ" ភាគីពាក់ព័ន្ធ អាចស្នើមកក្រសួងពាណិជ្ជកម្ម ដើម្បីអនុវត្តនីតិវិធីក្នុងការដកហូតម្ហូបអាហារ។

ទម្រង់និងបែបបទនៃការដកហូតនូវម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១១ ៖**

នីតិវិធីអនុវត្តចំពោះការដកហូតម្ហូបអាហារដោយអាជ្ញាបញ្ជា រួមមាន៖

ក- ក្នុងករណីដែលប្រតិបត្តិករអាជីវកម្មម្ហូបអាហារមិនអនុវត្តការដកហូតម្ហូបអាហារដោយខ្លួនឯង ក្រសួងពាណិជ្ជកម្មតម្រូវឱ្យប្រតិបត្តិករអាជីវកម្មម្ហូបអាហារនោះ ចាប់ផ្តើមអនុវត្តការដកហូតម្ហូបអាហារនិងត្រូវតាមដានត្រួតពិនិត្យការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព។

ខ- ដូចមានចែងក្នុងកថាខណ្ឌ "ក" ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងដល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ តាមរយៈលិខិត សារអេឡិចត្រូនិក ទូរសារ ប្រព័ន្ធទូរស័ព្ទ ឬតាមប្រព័ន្ធទំនាក់ទំនងផ្សេងៗទៀត ដោយភ្ជាប់ជាមួយលិខិតជាលាយលក្ខណ៍អក្សរអំពីព័ត៌មាននៃម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស រួមមានឈ្មោះ ទំហំសម្បកវេចខ្ចប់ លេខឡូត៍ទំនិញ ផលប៉ះពាល់សុខភាព ការមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ចំណាត់ថ្នាក់ នៃការដកហូតម្ហូបអាហារ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងវិធានការដែលប្រតិបត្តិករអាជីវកម្មម្ហូបអាហារនោះត្រូវអនុវត្តបន្ទាន់។

គ- បន្ទាប់ពីទទួលបានការជូនដំណឹងពីក្រសួងពាណិជ្ជកម្មឬក្រសួង ស្ថាប័នមានសមត្ថកិច្ច ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវចាប់ផ្តើមអនុវត្តការដកហូតម្ហូបអាហារជាបន្ទាន់ រួមមានការផ្អាកផលិតកម្ម ការផ្អាកការនាំចេញ ការផ្អាកការចែកចាយ ឬការផ្អាកធ្វើធុរកិច្ចម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ហើយត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នមានសមត្ថកិច្ច។ វិធានការនេះក៏ត្រូវអនុវត្តចំពោះឡូត៍ផ្សេងទៀតនៃមុខទំនិញដូចគ្នានេះផងដែរ។

ឃ- ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្មត្រូវចេញសេចក្តីជូនដំណឹងជាសាធារណៈអំពីម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស តាមរយៈប្រព័ន្ធផ្សព្វផ្សាយ សារអេឡិចត្រូនិក សារព័ត៌មាន ឬតាមមធ្យោបាយផ្សេងៗទៀត។

ង- ចំពោះម្ហូបអាហារដែលបាននាំចូលឬនាំចេញពីប្រទេសកម្ពុជា នីតិវិធីនៃការដកហូតម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ត្រូវអនុវត្តរួមគ្នាដោយក្រសួងពាណិជ្ជកម្មនិងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារឬអាជ្ញាធរនៃប្រទេសប្រភពដើម។

**មាត្រា១២ ៖**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលបានដកហូតម្ហូបអាហារដែលគ្មានសុវត្ថិភាពឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ត្រូវផ្តល់សំណងការខូចខាត ឬផ្តល់ម្ហូបអាហារ ឬផ្តល់ផលិតផលជំនួសវិញ។

**មាត្រា១៣ ៖**

លក្ខខណ្ឌតម្រូវក្នុងការអនុវត្តការដកហូតម្ហូបអាហារ រួមមាន៖

ក- ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវធានាថាម្ហូបអាហារដែលបានដកហូតត្រូវរក្សាទុកនៅទីតាំងមានសុវត្ថិភាពនិងដាក់នៅដោយឡែកពីផលិតផលផ្សេងៗទៀត។

ខ- ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវរក្សាកំណត់ត្រាម្ហូបអាហារដែលត្រូវបានដកហូតរួចហើយ រួមមាន ឈ្មោះ លេខឡូត៍ ទំហំ ប្រភេទ រូបភាព និងបរិមាណនៃម្ហូបអាហារ បន្ទាប់មកត្រូវផ្តល់របាយការណ៍មកក្រសួងពាណិជ្ជកម្ម។

គ-ម្ហូបអាហារដែលត្រូវបានដកហូតរួចហើយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងតឹងរ៉ឹងពីប្រតិបត្តិករអាជីវកម្មម្ហូបអាហារ រហូតដល់ម្ហូបអាហារទាំងនោះត្រូវបានកម្ទេចចោល កែច្នៃឬប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត ប៉ុន្តែមិនសម្រាប់ប្រើជាគ្រឿងឧបភោគបរិភោគរបស់មនុស្ស ហើយនីតិវិធីនៃការកម្ទេចចោលនិងការផ្លាស់ប្តូរគោលបំណងប្រើប្រាស់ចំពោះម្ហូបអាហារទាំងនោះត្រូវមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មនិង/ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ចំពោះការដកហូតម្ហូបអាហារស្ថិតក្នុងចំណាត់ថ្នាក់ទី១ ដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ ត្រូវតែកម្ទេចចោលជាដាច់ខាត។

ឃ- ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវផ្តល់របាយការណ៍ពីស្ថានភាពនៃការដកហូតម្ហូបអាហារជូនក្រសួងពាណិជ្ជកម្ម។ របាយការណ៍នេះត្រូវបញ្ជាក់អំពីព័ត៌មានសំខាន់ៗ ដូចខាងក្រោម៖

- ចំនួននិងឈ្មោះអ្នកលក់ អតិថិជន និងអ្នកប្រើប្រាស់ ដែលបានជូនដំណឹងពីការដកហូតម្ហូបអាហារ
- ចំនួននិងឈ្មោះអ្នកលក់ អតិថិជន និងអ្នកប្រើប្រាស់ ដែលមិនបានឆ្លើយតបនឹងការជូនដំណឹងពីការដកហូតម្ហូបអាហារនិងយន្តការចាំបាច់នានាចំពោះបុគ្គលមិនបានឆ្លើយតបនៃការជូនដំណឹង ដើម្បីធានាប្រសិទ្ធភាពនៃការដកហូតម្ហូបអាហារ
- បរិមាណម្ហូបអាហារដែលបានដកហូតរួចហើយនិងបរិមាណម្ហូបអាហារដែលមិនទាន់បានដកហូត
- រយៈពេលជាក់លាក់សម្រាប់ការបញ្ចប់ការដកហូតម្ហូបអាហារ។

**មាត្រា១៤.-**

ការបញ្ចប់ការដកហូតម្ហូបអាហារ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ក-ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវសហការជាមួយក្រសួងពាណិជ្ជកម្ម តាមរយៈលិខិត សារអេឡិចត្រូនិក ទូរសារ ទូរស័ព្ទ ឬតាមមធ្យោបាយផ្សេងៗទៀត ដើម្បីបញ្ចប់ការដកហូតម្ហូបអាហារ។

ខ-ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវបង្ហាញជូនក្រសួងពាណិជ្ជកម្មអំពីវិធានការក្នុងការកែតម្រូវនិងការការពារមិនឱ្យករណីដដែលកើតឡើងម្តងទៀត។

គ-ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យវាយតម្លៃល្អិតល្អន់រាល់របាយការណ៍ពីស្ថានភាពនៃការដកហូតម្ហូបអាហារ ការកែច្នៃម្ហូបអាហារឡើងវិញ របាយការណ៍កម្ទេចចោល និងវិធានការកែតម្រូវ ដើម្បីបង្ការករណីដដែលនេះកើតឡើងម្តងទៀត។ នៅពេលក្រសួងពាណិជ្ជកម្មយល់ឃើញថាគ្រប់គ្រាន់សមស្រប និងសម្រេចឯកភាពចំពោះប្រសិទ្ធភាពនៃការដកហូតម្ហូបអាហារនេះហើយ ក្រសួងពាណិជ្ជកម្មត្រូវចេញសេចក្តីប្រកាសបញ្ចប់ការដកហូតម្ហូបអាហារជាផ្លូវការ។

## ជំពូកទី៥

## ទណ្ឌកម្ម

**មាត្រា១៥.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលបំពាននឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលនិង/ឬទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ